# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:...០១ សរាណន**

## សារាចរណែនាំ
## ស្តីពីការប្រើប្រាស់គ្រូជាប់កិច្ចសន្យា

ផ្អែកតាមខ្លឹមសារនៃព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា និងគោលដៅនៃកំណែទំរង់រដ្ឋបាលសាធារណៈ រាជរដ្ឋាភិបាលយល់ព្រមលើសំណើរបស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការប្រើប្រាស់ជារៀងរាល់ឆ្នាំគ្រូជាប់កិច្ចសន្យាតាមតំរូវការជាក់ស្តែងរបស់មូលដ្ឋាន ។

កន្លងមកដើម្បីពង្រឹងគុណភាព និងប្រសិទ្ធភាពសេវាអប់រំ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ១០២ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកំណត់ការចំណាយដោយឡែកសំរាប់អនុវត្តកម្មវិធីសកម្មភាពជាអាទិភាពនៅក្រសួងអប់រំ យុវជន និងកីឡា ។ ទន្ទឹមនឹងនេះ ក្រសួងអប់រំ យុវជន និងកីឡា ក៏បាននិងកំពុងអនុវត្តការជាក់ស្តែងមួយចំនួនដើម្បីឆ្លើយតបនឹងតំរូវការសំណូមពរចាំបាច់ចំពោះ មុខដូចជា :

១. ការប្រឡងជ្រើសរើសគ្រូត្រូវបានរៀបចំដោយមានលក្ខណៈទន់ភ្លន់ និងដោយផ្តល់អាទិភាពពិន្ទុចំពោះបេក្ខជនដែលស្ម័គ្រចិត្តទៅបំរើការនៅតាមតំបន់ដាច់ស្រយាល និងជួបការលំបាក

២. ការបែងចែកគ្រូថ្មី ដែលបញ្ចប់ការបណ្តុះបណ្តាលអោយទៅបំរើការងារតាមសាលារៀនកំពុងខ្វះគ្រូ

៣. ការអនុវត្តន៏ការពង្រាយគ្រូតាមស្ថានភាពជាក់ស្តែងរបស់មូលដ្ឋានសាលារៀន

៤. ការបំផុសអោយបង្រៀនពីរពេល ពីរថ្នាក់ និងថ្នាក់គួប

៥. ការឧបត្ថម្ភជីវភាពបន្ថែមជូនគ្រូ ដែលបំរើការងារនៅតំបន់ដាច់ស្រយាល និងជួបការលំបាក ។

វិធានការទាំងអស់នេះ គឺជាការអនុវត្តន៏ជាក់ស្តែងតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ពិសេសកំណែទំរង់រដ្ឋបាលសាធារណៈ ក្នុងន័យរក្សាបរិមាណស្ថិររបស់មន្ត្រីរាជការស៊ីវិល ។

ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលអនុញ្ញាតអោយក្រសួងអប់រំ យុវជន និងកីឡា ជ្រើសរើសគ្រូជាប់កិច្ចសន្យាតាមការចាំបាច់ជាក់ស្តែង ក្នុងឆ្នាំនីមួយៗសំរាប់សាលារៀនដែលខ្វះគ្រូ ។ គ្រូជាប់កិច្ចសន្យាអាចប្រឡងចូលក្របខ័ណ្ឌរដ្ឋ ដែលបានកំណត់នៅក្នុងលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌគ្រូបង្រៀន ។ ចាប់ពីពេលនេះតទៅសំណើសុំចូលក្របខ័ណ្ឌជាស្វ័យប្រវត្តិ របស់គ្រូជាប់កិច្ចសន្យាមិនត្រូវបានអនុញ្ញាត ឡើយ ។

ទទួលបានសារាចរណែនាំនេះ ក្រសួងអប់រំ យុវជន និងកីឡា និងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តខ្លឹមសារខាងលើដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិកាដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិកាដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ន
- ឯកសារ-កាលប្បវត្តិ